**នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស និងភាសាខ្មែរ

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៦

**ឯកសារដើម**
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 20-Jun-2016, 10:21
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ **សាធារណៈ:/Public**

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហមេធាវីនាំមុខនៅនឹងសំណើលើកទីបួនរបស់ នួន ជា ស្តីពីមន្ទីរសន្តិសុខ និងការបោសសម្អាតផ្ទៃក្នុង**

---

**<u>ដាក់ដោយ៖</u>**

**<u>សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖</u>**

ពេជ អង្គ

Marie GUIRAUD

**<u>សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖</u>**

ជេត វណ្ណលី

ហុង គីមសួន

គីម ម៉េងឃី

ឡោ ជុនធី

ម៉ុច សុវណ្ណារី

**<u>នៅចំពោះមុខ៖</u>**

**<u>អង្គជំនុំជម្រះសាលាដំបូង៖</u>**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យូរ ឧត្តរា

ចៅក្រម Claudia FENZ

**<u>ផ្ញើជូន៖</u>**

**<u>ការិយាល័យសហព្រះរាជអាជ្ញា៖</u>**

Original EN:

សុិន សុវ៉ន

សំ សុគង់

វ៉ែន ពៅ

ទី ស្រីនណា

Laure DESFORGES
Ferdinand DJAMMEN NZEPA
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Yiqiang Y. LIU
Daniel LOSQ
Christine MARTINEAU
Lyma NGUYEN
Mahesh RAI
Nushin SARKARATI
Beini Ye

ជា លាង

Nicholas KOUMJIAN

**ជនជាប់ចោទ៖**

ខៀវ សំផន

នួន ជា

**សហមេធាវីការពារក្ដី៖**

សុន អរុណ

Victor KOPPE

គង់ សំអុន

Anta GUISSÉ

**មេធាវីប្រចាំការ៖**

ទូច វរល័ក្ស

Calvin SAUNDERS

**សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

Olivier BAHOUGNE
Patrick BAUDOUIN
Beini Ye

## I. សេចក្ដីផ្ដើម

1. សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ("សហមេធាវីនាំមុខ") សូមឆ្លើយតបសំណើលើកទីបួនរបស់ នួន ជា សុំសាក្សី សម្រាប់វគ្គមន្ទីរសន្តិសុខ និងការបោសសម្អាតផ្ទៃក្នុង ក្នុងសំណុំរឿង ០០២/០២[1]។

## II. ច្បាប់ជាធរមាន

2. វិធាន៨៧(៤)នៃវិធានផ្ទៃក្នុងផ្ដល់ឲ្យអង្គជំនុំជម្រះនូវសិទ្ធិកោះហៅ ឬស្ដាប់សក្ខីកម្មរបស់ជនណាម្នាក់ក្នុងនាមជាសាក្សី ដែលភស្តុតាងរបស់ជននោះអាចនាំទៅដល់ការបញ្ជាក់ការពិត បន្ទាប់ពីមានសំណើដែលមានសំអាងហេតុពីសំណាក់ភាគីនៃកិច្ចដំណើរការនីតិវិធី។ វិធានដដែលនេះដាក់សំណើនេះក្រោមលក្ខខណ្ឌវិនិច្ឆ័យដូចមានចែងក្នុងវិធាន ៨៧(៣) ដែលកំណត់ *ក្នុងចំណោមប្រការផ្សេងៗ* ថាសក្ខីកម្មនេះមិនត្រូវ "មិនជាប់ពាក់ព័ន្ធ ឬជាការស្នើសុំជាន់គ្នា"[2]។ បន្ថែមពីលើនេះ ភាគីដែលស្នើសុំត្រូវតែធ្វើឲ្យអង្គជំនុំជម្រះជឿជាក់ថាសក្ខីកម្មដែលត្រូវបានស្នើសុំ ពុំអាចរកបាននៅមុនពេលនៃការចាប់ផ្ដើមជំនុំជម្រះ[3]។

3. អង្គជំនុំជម្រះសាលាដំបូងពីពេលមុនបានបដិសេធពុំកោះហៅបុគ្គលនានា ក្នុងករណីដែលខ្លួនពិចារណាឃើញថាសក្ខីកម្មដែលត្រូវបានស្នើសុំ (i) ទំនងជាច្រំដែលទៅនឹងសក្ខីកម្មរបស់សាក្សីដែលបានផ្ដល់សក្ខីកម្មរួចហើយ[4] (ii) គ្មានអ្វីដែលអាចឆ្លើយបំភ្លឺបានពាក់ព័ន្ធនឹងតួនាទីរបស់ជនជាប់ចោទក្នុងព្រឹត្តិការណ៍ពាក់ព័ន្ធ[5] (iii) ទំនងគ្រាន់តែជាការគូសបញ្ជាក់ទៅលើអង្គហេតុតែប៉ុណ្ណោះ

---

[1] សំណើលើកទីបួនរបស់ នួន ជា សុំសាក្សីសម្រាប់វគ្គមន្ទីរសន្តិសុខ និង "ការបោសសម្អាតផ្ទៃក្នុង" ក្នុងសំណុំរឿង ០០២/០២ (ដំណើរការមន្ទីរសន្តិសុខ ស-២១ និងភស្តុតាងជាឯកសារ), ឯកសារ E412, ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៦ ("សំណើលើកទីបួន")។

[2] វិធាន៨៧(៣)(ក)នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ* សេចក្ដីសម្រេចស្ដាពរស្ដីពីសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០២/០១, ឯកសារ E312, ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ("សេចក្ដីសម្រេចស្ដាពរស្ដីពីសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០២/០១"), កថាខណ្ឌ ១២៤។ សាលក្រមជំនុំជម្រះ ឌុច, ឯកសារ E188, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០, កថាខណ្ឌ ៤១។

[3] វិធានផ្ទៃក្នុង ៨៧(៤)។

[4] សេចក្ដីសម្រេចស្ដាពរស្ដីពីសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០២/០១, កថាខណ្ឌ ៧១។

[5] *ដូចឯកសារយោងខាងលើ*, កថាខណ្ឌ ៧៥។

ហេតុដូច្នេះ អង្គជំនុំជម្រះពុំចាំបាច់ស្ដាប់សក្ខីកម្មគាត់ក្នុងសវនាការឡើយ[6] ឬ (iv) ច្រំដែលជាមួយនឹងភ័ស្ដុតាងដែលអង្គជំនុំជម្រះធ្លាប់បានស្ដាប់ពីមុនរួចមកហើយ[7]។

4. វិធាន២១(១)(ក) និង២១(៤)នៃវិធានផ្ទៃក្នុងចែងថា ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ និងត្រូវធ្វើការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប។

5. វិធាន៨៥ នៃវិធានផ្ទៃក្នុង ចែងថា ប្រធានអង្គជំនុំជម្រះ ត្រូវធានាដល់ការអនុវត្តសិទ្ធិការពារខ្លួនឲ្យប្រព្រឹត្តទៅបានដោយសេរី និងអាចបដិសេធនូវរាល់នីតិវិធីដែលនាំឲ្យមានការពន្យាពេលដល់ការជំនុំជម្រះ និងដែលមិនអាចនាំទៅដល់ការស្វែងរកការពិត។

## III. ចម្លើយតប

### ក. ចម្លើយតបទៅនឹងសំណើសុំពន្លឿនការកោះហៅ លី ហ៊ (2-TCW-956)

6. សំណើនេះផ្ដល់ទឡ្ហីករណ៍ដើម្បីពន្លឿនការផ្ដល់សក្ខីកម្មរបស់ លី ហ៊ សម្រាប់វគ្គសវនាការដែលកំពុងដំណើរការស្ដីពីមន្ទីរសន្ដិសុខ និងការបោសសម្អាតផ្ទៃក្នុង ដើម្បីឲ្យគាត់មានលទ្ធភាពផ្ដល់សក្ខីកម្ម *ក្នុងចំណោមចំណុចផ្សេងៗ* អំពីការប្រព្រឹត្តិរបស់អ្នកសួរចម្លើយ និងការបញ្ជូនអ្នកទោសពី ស ២១ ទៅព្រៃស[8]។ សំណើនេះកត់សម្គាល់ថា "លី ហ៊ (2-TCW-956) ផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងសំណុំរឿង០០១ ក្នុងនាមជាដើមបណ្ដឹងរដ្ឋប្បវេណី"។ ទោះជាយ៉ាងនេះក្ដី ចុងក្រោយ អង្គជំនុំជម្រះបានច្រានចោលពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដោយផ្អែកលើសាលក្រមសំណុំរឿង០០១ របស់អង្គជំនុំជម្រះសាលាដំបូង[9]។

---

[6] *ដូចឯកសារយោងខាងលើ*។

[7] *ដូចឯកសារយោងខាងលើ*, កថាខណ្ឌ ៧៥, ៧៨, ៨២, ១៣៣។

[8] សំណើ កថាខណ្ឌ ២៥

[9] សំណើ កថាខណ្ឌ ២៦

7. លី ហរ បានផ្តល់សក្ខីកម្មជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០១ [10] ហើយត្រូវបានអង្គជំនុំជម្រះសាលាដំបូងបដិសេធថាគាត់ពុំមែនជាជនរងគ្រោះដោយផ្ទាល់នៅ ស២១ ឡើយ [11]។ ទោះបីយ៉ាងនេះក្តី នៅពេលដាក់ភស្តុតាងបន្ថែម សំណើនេះខកខានពុំបានលើកឡើងថា អង្គជំនុំជម្រះតុលាការកំពូល ក្នុងសំណុំរឿង០០១ ជឿជាក់ថា លី ហរ គឺជាអ្នកជាប់ឃុំឃាំងនៅស២១ និងបានច្រានចោលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងបានទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់[12] ដោយផ្តល់សំអាងហេតុថា៖

> អង្គជំនុំជម្រះសាលាដំបូង ពុំចាំបាច់យល់ឲ្យបានប្រាកដថា “លី ហ៊ ត្រូវទទួលស្គាល់ថាជា អ៊ា ហរ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះទេ។ អ្វីដែលសំខាន់នោះ គឺថាអ្នកដាក់ពាក្យសុំដែលពេលបច្ចុប្បន្នប្រើឈ្មោះ លី ហ៊ ជាបុគ្គលតែមួយដែលជាប់នៅមន្ទីរឃុំឃាំង ស ២១ ជាឈ្មោះ អ៊ា ហ៊រ។ នៅពេលសវនាការលើបណ្តឹងសាទុក្ខ ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណី បានដាក់ភស្តុតាងបន្ថែមដែលបង្ហាញថាឈ្មោះឪពុកម្តាយរបស់គាត់ត្រូវគ្នាជាមួយឈ្មោះឪពុកម្តាយរបស់អ៊ា ហ៊រ និងបានផ្តល់នូវស្នាមមេដៃរបស់គាត់ដែលត្រូវគ្នាជាមួយនឹងស្នាមមេដៃនៅលើចម្លើយសារភាពរបស់នៅមន្ទីរ ស ២១។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល ទទួលស្គាល់អត្តសញ្ញាណរបស់អ្នកដាក់ពាក្យសុំថាជាជនរងគ្រោះនៅមន្ទីរ ស ២១ និង ស ២៤ ហើយសម្រេចបដិសេធសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ”[13]។

8. ក្នុងសំណុំរឿង០០២ លី ហ៊ បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី កាលពីថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៨[14]។ កាលពីថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១០ គាត់ត្រូវបានសហចៅក្រមស៊ើបអង្កេត ទទួលស្គាល់ថាជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានទទួលរងព្យសនកម្មជាជនរងគ្រោះដោយផ្ទាល់នៅស២១[15]។ កាលពីថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០១១ ក្រុមមេធាវីការពារក្តី នួន ជា បានដាក់បញ្ចូល លី ហ៊ នៅក្នុងបញ្ជីនៃសេចក្តីសង្ខេបអំពី “សាក្សី” ដើម្បីផ្តល់សក្ខីកម្មអំពីបទពិសោធន៍របស់ខ្លួនជាអតីតអ្នកជាប់ឃុំឃាំងនៅស២១ និងដើម្បីធ្វើការបញ្ជាក់លើចំណុច

---

[10] សំណុំរឿង ០០១, ប្រតិចារឹកនៃកិច្ចដំណើរការសវនាការ, ថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ ២០០៩ ,E3/7454, *សូមមើលផងដែរ* ដីកាកោះ ដើមបណ្តឹងរដ្ឋប្បវេណី, D288/6.83, ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៩

[11] សំណុំរឿង ០០១, សាលក្រមអង្គជំនុំជម្រះសាលាដំបូង, E188, ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៩, កថាខណ្ឌ ៦៤៧

[12] សំណុំរឿង ០០១, សាលដីកាលើបណ្តឹងសាទុក្ខ, F28, ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១២, កថាខណ្ឌ ៥៣៩-៥៤០

[13] សំណុំរឿង ០០១, សាលដីកាលើបណ្តឹងសាទុក្ខ, F28, ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១២, កថាខណ្ឌ ៥៤០

[14] D22/2025

[15] ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានអាសយដ្ឋាននៅក្នុងខេត្តបន្ទាយមានជ័យ, D416, ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១០, ទំព័រ ៩, ១១

មួយចំនួន រួមទាំង ភាពអាចជឿជាក់បាននៃសក្ខីកម្មរបស់ឧុច[16]។ កាលពីថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៤ ក្រុមមេធាវីការពារក្តី នួន ជា បានដាក់បញ្ចូលគាត់នៅក្នុងបញ្ជី "សាក្សី" នៅក្នុងបញ្ជីដែលបានធ្វើបច្ចុប្បន្នភាពនៃឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានស្នើឡើងសម្រាប់សំណុំរឿង០០២/២ [17]។

9. សហមេធាវីនាំមុខយល់ឃើញថា លេខចូល ១៤.២២៤ នៅក្នុងបញ្ជីអ្នកទោសរបស់ ក.ស.ច.ស ដែលដូចគ្នាទៅនឹងឈ្មោះ អ៊ា ហ៊ រ គឺផ្អែកលើបញ្ជីនៃចម្លើយសារភាពរបស់អ្នកទោសនៅទួលស្លែង [18]។ ព័ត៌មាននេះ ដូចទៅនឹងព័ត៌មានអំពីប្រវត្តិរូប នៅក្នុងចម្លើយសារភាពរបស់លី ហ៊ ដែលមាននៅក្នុងសំណុំរឿង[19]។

10. ទោះជាយ៉ាងនេះក្តី សហមេធាវីនាំមុខត្រូវបានមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជូនដំណឹងថា លី ហ៊ បានទទួលអនិច្ចកម្មទៅហើយ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំព័ត៌មាន បន្ថែមពីអង្គភាពគាំពារជនរងគ្រោះ ទាក់ទងនឹងលិខិតបញ្ជាក់ពីមរណភាពរបស់គាត់ និងការស្នើសុំតាំងខ្លួនសិទ្ធិវ័ន្ត[20]។ អង្គភាពគាំពារជនរងគ្រោះបានផ្តល់ឯកសារដែលប្រមូលបានទាក់ទងនឹងការស្នើ សុំតាំងខ្លួនជាសិទ្ធិវ័ន្តដល់សហមេធាវីនាំមុខ[21]។ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបាន

---

[16] សម្ភារៈឯកសារក្នុងការរៀបចំសម្គាប់កិច្ចដំណើរការសវនាកា, បញ្ជីបឋម៖ សេចក្តីសង្ខេបអំពីសាក្សី - ក្រុមមេធាវីការពារក្តី នួន ជា, E93/4.3, លេខចូល ២៦៧, ទំព័រ ៧៩

[17] សេចក្តីសង្ខេបអំពីសាក្សី ដែលបានធ្វើបច្ចុប្បន្នភាព, E305/4.2, លេខចូល១៧, ទំព័រ៩។ អង្គជំនុំជម្រះសាលាដំបូង ពន្យារពេលការផ្តល់សក្ខីកម្មរបស់បុគ្គលមួយចំនួន ដែលភាគី បានស្នើសុំការសួរដេញដោល នៅក្នុង "សវនាការនាពេលអនាគត"។ *សូមមើលផងដែរ* សេចក្តីសម្រេចចុងក្រោយស្តីពីសាក្សី, អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវស្តាប់សក្ខីកម្មក្នុងសំណុំរឿង០០២/១, E312, ថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤, ទំព័រ១២៧

[18] E3/10510 ERN 00161117 ជាភាសាខ្មែរ, ទំព័រ៤៦, លេខចូល ៤០

[19] E3/9216 ERN 0036172 ជាភាសាអង់គ្លេស, ERN 00279916 ជាភាសាខ្មែរ, ទំព័រ ១

[20] *សូមមើលផងដែរ* ឧបសម្ព័ន្ធ I (សម្ងាត់)។ ដើម្បីប្រយោជន៍របស់ភាគី សហមេធាវីនាំមុខ សូមបញ្ជាក់ថាការស្នើសុំតាំងខ្លួនជាសិទ្ធិវ័ន្ត ត្រូវបានដើមបណ្តឹងរដ្ឋប្បវេណី ដាក់ជូនអង្គជំនុំជម្រះសាលាដំបូង តាមរយៈអង្គភាពគាំពារជនរងគ្រោះ។ សហមេធាវីនាំមុខ ពុំមានសិទ្ធិជាស្វ័យប្រវត្តិក្នុងការចូលមើលព័ត៌មានបែបនោះ ឬពិនិត្យមើលដំណើរការនោះឡើយ។

[21] *សូមមើលផងដែរ* ឧបសម្ព័ន្ធ II (សម្ងាត់ និង*សម្រាប់ភាគីតែម្ខាង*) ដែលមានឯកសារ ដែលទទួលបន្ទាប់សហមេធាវីនាំមុខបានដាក់សំណើនៅក្នុង ឧបសម្ព័ន្ធ I។ ឧបសម្ព័ន្ធនេះ មានឯកសារមួយច្បាប់ទាក់ទងនឹងសំណើសុំតាំងខ្លួនជាសិទ្ធិវ័ន្ត ដែលអង្គភាពគាំពារជនរងគ្រោះកំពុងរបចំដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ សហមេធាវីនាំមុខ ទទួលបានដំណឹងថា

ទំនាក់ទំនងជាមួយសហព័ន្ធរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ហើយទទួលបានព័ត៌មានដូចគ្នា។ ផ្អែកលើព័ត៌មានដែលទទួលបានពីអង្គភាពគាំពារជនរងគ្រោះ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និង សហព័ន្ធរបស់ដើមបណ្ដឹងរដ្ឋប្បវេណី សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសូម អះអាងថា ដើមបណ្ដឹងរដ្ឋប្បវេណីបានទទួលអនិច្ចកម្មទៅហើយ។ ដូច្នេះ សំណើសុំពន្លឿនការផ្ដល់ សក្ខីកម្ម ឬកោះហៅដើមបណ្ដឹងរដ្ឋប្បវេណីឲ្យមកផ្ដល់សក្ខីកម្ម ពុំនឹងទទួលបានលទ្ធផលអ្វីឡើយ។

## ខ) ចម្លើយតបទៅនឹងសំណើកោះហៅអ្នករៀបចំបញ្ជីឈ្មោះអ្នកទោស របស់ ក.ស.ច.ស

11. សំណើនេះសុំឲ្យកោះហៅសាក្សីទី១ និងសាក្សីទី២ "អ្នករៀបចំបញ្ជីអ្នកទោសរបស់ ក.ស.ច.ស" ដើម្បីផ្ដល់ "ការពន្យល់លម្អិត" *ក្នុងចំណោមចំណុចផ្សេងៗ* អំពីវិធីសាស្ត្រដែលបានអនុវត្តលក្ខណៈនៃឯកសារច្បាប់ដើម ដែលពួកគាត់បានយកមកធ្វើជាសំអាង និងការជ្រើសរើសឯកសារនោះ" ពីព្រោះការបញ្ជាក់ពីអ្នកស៊ើបអង្កេតទាំងនេះ "គឺកាន់តែមានសារៈសំខាន់ថែមទៀត ដោយសារបញ្ជីឈ្មោះរបស់ ក.ស.ច.ស គឺជាឯកសារគន្លឹះសំខាន់មួយសម្រាប់ភាគីយោងនៅក្នុងអំឡុងវគ្គសវនាការដែលកំពុងដំណើរការនេះ យថាភាព និងភាពអាចជឿជាក់បាន ដែលវាសំខាន់សម្រាប់ការបញ្ជាក់ការពិត"[22] ។

12. សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសន្និដ្ឋានថា បញ្ជីអ្នកទោស ស២១ ដែលត្រូវបានរៀបចំឡើងដោយសហចៅក្រមស៊ើបអង្កេត (បញ្ជីអ្នកទោស ស២១ របស់ ក.ស.ច.ស) ដែលត្រូវបានទទួលយក អនុលោមតាមសេចក្ដីសម្រេច E393 នោះ ត្រូវបានរៀបចំដោយក្រុមស៊ើបអង្កេត[23]។ ឯកសារសំខាន់ៗ ដែលជាមូលដ្ឋាននៃបញ្ជីឈ្មោះនេះ ត្រូវបានទទួលយកជាភស្តុតាង

---

ឯកសារទាំងនេះ ត្រូវបានដាក់ជូនអង្គជំនុំជម្រះសាលាដំបូង ប៉ុន្តែ ត្រូវបានច្រានចោលពីព្រោះ ឈ្មោះបុគ្គល ត្រូវបានប្រកបខុសពីនៅក្នុងលិខិតបញ្ជាក់អំពីមរណភាព។ សហមេធាវីនាំមុខ ស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង ធ្វើការប្រៀបធៀបព័ត៌មានអំពីប្រវត្តិរូបនៅក្នុងចម្លើយសារភាពនៅ ស ២១ របស់ដើមបណ្ដឹងរដ្ឋប្បវេណី និងលិខិតបញ្ជាក់អំពីមរណភាព ដើម្បីពិចារណាឡើងវិញក្នុងការចាត់វិធានការបន្ថែមទាក់ទងនឹងសំណើសុំតាំងខ្លួនជាសិទ្ធិវ័ន្ត។

[22] សំណើ, កថាខណ្ឌ៣៤

[23] *សូមមើល* បញ្ជីឈ្មោះអ្នកទោសនៅ ស ២១ របស់ ក.ស.ច.ស និងការពន្យល់អំពីវិធីសាស្ត្រដែលត្រូវអនុវត្ត, E393.1,ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦, កថាខណ្ឌ ២, ៤-៦

នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[24]។ ឯកសារទាំងនេះគឺជា "ឯកសារដែលបន្សល់ទុកតាំងពីសម័យខ្មែរក្រហម ដែលត្រូវប្រមូលពីទួលស្លែង និងមជ្ឈមណ្ឌលឯកសារកម្ពុជា"[25]។

13. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថា សំណើជាក់លាក់នេះ ផ្អែកលើថា តើអង្គជំនុំជម្រះសាលាដំបូង និងភាគី មានបំណងប្រើប្រាស់ "បញ្ជីឈ្មោះរបស់ ក.ស.ច.ស" ដែលត្រូវបានរៀបចំឡើងដោយអ្នកស៊ើបអង្កេត ធ្វើជាភស្តុតាង ដែរឬទេ។

14. ដោយពុំទទួលបានសេចក្តីពន្យល់ពីអង្គជំនុំជម្រះសាលាដំបូង សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថា គោលបំណងនៃបញ្ជីអ្នកទោស ស២១ ដែលរៀបចំដោយ ក.ស.ច.ស គឺដើម្បីជួយដល់អង្គជំនុំជម្រះសាលាដំបូង និងភាគី ឲ្យទទួលបានប្រយោជន៍ពីការងារដែល ក.ស.ច.ស បានរៀបចំរួចហើយ និងដើម្បីឲ្យមានភាពងាយស្រួលក្នុងការពិនិត្យមើលឈ្មោះ និងព័ត៌មាន ដែលទាក់ទងនឹងអ្នកទោស និងឯកសារសំខាន់ៗ។

15. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី គាំទ្រសំណើសុំដាក់ឯកសារ ដែលជាមូលដ្ឋាននៃបញ្ជីឈ្មោះអ្នកជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខ ស២១ របស់ ក.ស.ច.ស ដោយហេតុថា វានឹងផ្តល់លទ្ធភាពពេញលេញដល់ភាគី និងអង្គជំនុំជម្រះសាលាដំបូង ក្នុងការពិនិត្យមើលប្រភពនៃការដាក់បញ្ចូលឈ្មោះនីមួយៗទៅក្នុងបញ្ជីឈ្មោះអ្នកជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខ ស២១ ដែលរៀបចំដោយ ក.ស.ច.ស។ ដូច្នេះភាគី និងអង្គជំនុំជម្រះសាលាដំបូង អាចផ្ទៀងផ្ទាត់មាតិកានៃការដាក់បញ្ចូលនីមួយៗ ជាមួយនឹងឯកសារជាក់ស្តែងដែលបានបន្សល់ទុកពីសម័យនោះ និងប្រើប្រាស់ដូចគ្នានៅក្នុងតុលាការ។

16. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីក៏លើកឡើងដែរថា ការអនុវត្តដូច្នេះផ្តល់លទ្ធភាពឲ្យភាគី និងអង្គជំនុំជម្រះសាលាដំបូង ផ្អែកលើឯកសារដែលបានបន្សល់ទុកពីសម័យនោះ ជាជាងផ្អែកលើបញ្ជីឈ្មោះអ្នកជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខ ស២១ ដែលរៀបចំដោយ ក.ស.ច.ស *ធ្វើជាភស្តុតាង*។ ផ្អែកលើការយល់ឃើញដូច្នេះ ខណៈដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងអំពីព័ត៌មានដែលពាក់ព័ន្ធនៅក្នុងបញ្ជីឈ្មោះអ្នកជាប់ឃុំឃាំងនៅ

---

[24] ការទទួលយកឯកសារនានាដែលជាមូលដ្ឋាននៃបញ្ជីឈ្មោះអ្នកជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខ ស២១ ដែលការិយាល័យសហចៅក្រមស៊ើបអង្កេត (ក.ស.ច.ស) បានបង្កើតឡើង, E393/1, ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៦, កថាខណ្ឌ ១

[25] *សូមមើល* បញ្ជីឈ្មោះអ្នកទោសនៅ ស ២១ របស់ ក.ស.ច.ស និងការពន្យល់អំពីវិធីសាស្ត្រដែលត្រូវអនុវត្ត, E393.1, ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦, កថាខណ្ឌ ៣

មន្ទីរសន្តិសុខ ស២១ ដែលរៀបចំដោយ ក.ស.ច.ស ក្នុងអំឡុងពេលដែលពួកគាត់សួរដេញដោល ក្នុងសវនាការនោះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីតែងតែប្រើប្រាស់ឯកសារ ដែលបន្សល់ទុកពីសម័យនោះធ្វើជាមូលដ្ឋាន នៅក្នុងតុលាការ។ សហមេធាវីនាំមុខតំណាងដើម បណ្តឹងរដ្ឋប្បវេណីជឿជាក់ថា ភាគី និងអង្គជំនុំជម្រះសាលាដំបូង ក៏មានការយល់ឃើញដូច្នេះ ដែរ។

17. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថា វាជាសិទ្ធិសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការកោះហៅអ្នករៀបចំបញ្ជីឈ្មោះអ្នកជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខ ស២១ របស់ ក.ស.ច.ស។ ក៏ប៉ុន្តែ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា ការយល់ព្រមតាមសំណើនេះ មានភាពចាំបាច់ តែនៅពេលដែលអង្គជំនុំជម្រះសាលាដំបូងចាត់ទុកថា បញ្ជីឈ្មោះអ្នកជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខ ស២១ ដែលរៀបចំដោយ ក.ស.ច.ស គឺជាភស្តុតាងផ្ទាល់ខ្លួន មិនមែនជាឧបករណ៍ប្រើប្រាស់ដើម្បីជួយដល់ភាគីទេនោះ។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបន្តការប្រើប្រាស់តែឯកសារដែលបន្សល់ទុកពីសម័យនោះនៅក្នុងតុលាការនោះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា សំណើដើម្បីកោះហៅអ្នករៀបចំបញ្ជីឈ្មោះអ្នកជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខ ស២១ របស់ ក.ស.ច.ស គឺជាការអនុវត្តជាន់គ្នា។

18. សំណើនេះលើកឡើងថា មាន "ចម្ងល់យ៉ាងខ្លាំងរួចទៅហើយអំពីវិធីសាស្រ្តដែលបានយកមកប្រើប្រាស់ ដើម្បីចងក្រងបញ្ជីឈ្មោះនេះ ជាពិសេសទាក់ទិននឹងការប្រើប្រាស់ឯកសារ និងការរៀបចំទិន្នន័យ"[26]។ សំណើនេះលើកឧទាហរណ៍មួយចំនួន ក្នុងនោះមាន បុគ្គលចំនួន ៤០៦ នាក់ នៅក្នុងបញ្ជី ដែលពុំមានកាលបរិច្ឆេទចូល កាលបរិច្ឆេទចាប់ខ្លួន និងការសម្លាប់ឡើយ"[27]។ ទោះបីជាសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើការសង្កេតទៅលើចរិតលក្ខណៈនៃបញ្ជីឈ្មោះអ្នកជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខ ស២១ របស់ ក.ស.ច.ស ក៏ដោយ ក៏សហមេធាវីនាំមុខពិនិត្យឃើញថា លេខចូលទាំងអស់ ដែលបានរៀបរាប់នៅក្នុងសំណើ[28] លើកលែងតែមួយ[29] ទទួល

[26] សំណើ, កថាខណ្ឌ ៣៣

[27] *ដូចជើងទំព័រខាងលើ*

[28] សំណើ, ជើងទំព័រ ៩៥

[29] សំណើ ជើងទំព័រ៩៥ សូមលើកឡើងផងដែរ លេខចូល ១៤,៩៣៨ ដែលផ្អែកលើចម្លើយសារភាពនៅ ស ២១ (TSL 1146)។ ចម្លើយសារភាព ពុំបញ្ជាក់ពីកាលបរិច្ឆេទនៃការចូល ប៉ុន្តែលើកឡើងថាបុគ្គលនោះ ក៏មានចម្លើយសារភាពលើកទី២ នៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៧៥ ( ERN 01219672ជាភាសាខ្មែរ)

បានពីបញ្ជីចម្លើយសារភាពនៅ សព២១ របស់ ក.ស.ច.ស ដែលត្រូវបានរៀបចំឡើងដោយបុគ្គលិកនៅទួលស្លែង និងវាយអត្ថបទដោយមជ្ឈមណ្ឌលឯកសារកម្ពុជា[30]។ លេខនៃចម្លើយសារភាពនៅ សព២១ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា សម្រាប់លេខចូលនីមួយៗ ត្រូវបានដាក់បញ្ចូលនូវលេខដូចគ្នានៅក្នុងបញ្ជីឈ្មោះអ្នកជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខ សព២១ របស់ ក.ស.ច.ស [31]។ សំណើនេះ លើកឡើងអំពីភាពមិនប្រក្រតីនៃព័ត៌មានដែលបានដាក់បញ្ចូលក្នុងបញ្ជីឈ្មោះអ្នកជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខ សព២១ របស់ ក.ស.ច.ស ដោយមិនបានស្នើឲ្យទទួលយកចម្លើយសារភាព សព២១ ដើម ដែលជាមូលដ្ឋានសំខាន់នោះទេ។

19. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមឲ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាថា តើជាការប្រើប្រាស់ធនធានដ៏មានប្រសិទ្ធភាពដែរឬទេដែលត្រូវទទួលយកចម្លើយសារភាពនៅ សព២១ ទាំងនោះ (តាមសំណើរបស់ភាគីណាមួយ)។ ដូច្នេះ ត្រូវធ្វើការវាយតម្លៃដោយឯករាជ្យមួយ ប្រសិនបើចាំបាច់។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីយល់ ឃើញថា ទោះបីអង្គជំនុំជម្រះសាលដំបូងសម្រេចចិត្តកោះហៅសាក្សីទាំងពីរនាក់ ឬម្នាក់ក្នុងចំណោមទាំងពីរនាក់នេះក៏ដោយ ក៏ការសួរដេញដោលលើចំណុចនេះដោយក្រុមមេធាវីការពារក្តី នួន ជា នឹងពុំមានភាពពេញលេញឡើយ ប្រសិនបើមិនទទួលយកចម្លើយសារភាព សព២១ ទាំងនេះទេនោះ។

20. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ធ្វើការស្រាយបំភ្លឺជាលាយលក្ខណ៍អក្សរអំពីប្រភពដើមនៃឯកសារសំខាន់ថ្មីដែលបន្សល់ទុកពីសម័យខ្មែរក្រហមជាមុនសិន មុននឹងសម្រេចលើសំណើសុំកោះហៅសាក្សីទី១ និងសាក្សីទី ២។

---

[30] *សូមមើល* E3/105010 ERN 00161072-00161348 ជាភាសាខ្មែរ។ បញ្ជីឈ្មោះអ្នកទោស សព២១ របស់ ក.ស.ច.ស មានលេខចូលចំនួន៧០៥ ដែលលេចចេញពីឯកសារនេះ។

[31] *សូមមើល ឧទាហរណ៍* លេខចូល ១៤,០៩៩ (ចម្លើយសារភាព សព២១ លេខក២១), លេខចូល ១៤,១៦០ (ចម្លើយសារភាព សព២១ លេខ គ២០០), លេខចូល ១៤,២៣៨ (ចម្លើយសារភាព សព២១ លេខ ជ៩១), លេខចូល ១៤,៣៧៤ (ចម្លើយសារភាព សព២១ លេខ ឌ ១៧), លេខចូល ១៤,៥០២ (ចម្លើយសារភាព សព២១ លេខ ត៣២២), លេខចូល ១៤,៥៨៣ (ចម្លើយសារភាព សព២១ លេខ ភ៣៩២), លេខចូល ១៤,៦៧៧ (ចម្លើយសារភាព សព២១ លេខ ល៦), លេខចូល ១៤,៦៨៩ (ចម្លើយសារភាព សព២១ លេខ ល៩១), លេខចូល ១៤,៦៩០ (ចម្លើយសារភាព សព២១ លេខ ល៩៣)

(គ) ចម្លើយតបទៅនឹងសំណើកោះហៅសាក្សីដែលនៅសល់

20. ចំពោះសាក្សីដែលនៅសល់ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី យល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងជាអ្នកធ្វើការសម្រេចទៅលើចំណុចនេះ។

## IV សំណើ

21. សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីស្នើដោយក្ដីគោរពឲ្យអង្គជំនុំជម្រះសាលាដំបូង៖

(១) **សម្រេចថា** អង្គជំនុំជម្រះនឹងមិនពិចារណាលើសំណើសុំកោះហៅសាក្សី លី ហ៊ា ឡើយ

(២) **ពិចារណាទៅ**លើសេចក្ដីសង្កេតដែលបានលើកឡើងនៅក្នុងសារណានេះ ទាក់ទិននឹងការកោះហៅសាក្សីទី១ និងសាក្សីទី២។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ២០ ខែ មិថុនា ឆ្នាំ ២០១៦ | ពេជ អង្គ<br>សហមេធាវីនាំមុខ | ភ្នំពេញ | |
| | Marie GUIRAUD<br>សហមេធាវីនាំមុខ | ភ្នំពេញ | |